ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ០៩ ខែឧសភា ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែមេសា ឆ្នាំ២០១៤

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំខែមេសា ឆ្នាំ២០១៤ របស់អគ្គនាយកដ្ឋានពន្ធដារ អង្គប្រជុំដឹកនាំដោយឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមពីឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។



ជាកិច្ចចាប់ផ្តើមឯកឧត្តម **គង់ វិបុល** បានសំដែងអំណរសាទរដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារ ដែលសំរេចបានប្រចាំខែមេសា ឆ្នាំ២០១៤ និងជំរុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារ សមាជិកអង្គប្រជុំ ដែលជាតំណាងមន្ត្រីពន្ធដារទូទាំងប្រទេសឲ្យខិតខំជំនះការលំបាកនិងបញ្ហាប្រឈមនានា ខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទឲ្យបានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង បង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានប្រសើរ ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេវាងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែងនិងអនុវត្តវិធានការនានាសំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៤។

ក្នុងខែមេសា ឆ្នាំ២០១៤នេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលនិងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ៥៧៦,៩៣៩ លានរៀល (គិតជាដុល្លារ ប្រមាណ ១៤៤.២ លានដុល្លារ) ដែលចំណូលពន្ធសម្រាប់

ខែមេសានេះ មានការកើនឡើងលើសខែមីនា ឆ្នាំ២០១៤ ប្រមាណចំនួនស្មើនឹង ៦៩.៤% ដែលក្នុងនោះថវិការដ្ឋមានការកើនឡើងស្មើនឹង ៨០.៤%។ ប្រសិនបើប្រៀបធៀបទៅនឹងចំណូលពន្ធប្រចាំខែមេសា ឆ្នាំ ២០១៣ មានការកើនឡើងស្មើនឹង ៣.៦% ក្នុងនោះថវិការដ្ឋកើនឡើងចំនួនស្មើនឹង ៥.២%។





ក្នុងរយៈពេលបួនខែនៃឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារ ប្រមូលចំណូលពន្ធដារនិងបង់ចូលថវិកាជាតិ បានចំនួនស្មើនឹង៣៦.៥៧%នៃគោលដៅកំណត់ដោយច្បាប់។ បើប្រៀបធៀបនឹងរយៈពេល បួនខែដូចគ្នានៃឆ្នាំ២០១៣ ឃើញថា ការប្រមូលចំណូលពន្ធដារចូលថវិកាជាតិសម្រាប់រយៈពេលបួនខែនៃឆ្នាំ២០១៤ នេះ មានការកើនឡើងចំនួនស្មើនឹង ៩.៥% ក្នុងនោះរួមមានថវិការដ្ឋកើនឡើងចំនួនស្មើនឹង ១០.១% និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិកើនឡើងចំនួនស្មើនឹង ៤.១%។

តាមការវិភាគប្រភេទពន្ធឃើញថា ចំណូលក្នុងឆ្នាំ២០១៤ មានការកើនឡើងគ្រប់ប្រភេទពន្ធ ក្នុងនោះប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើងមានដូចជា ពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ ២៣.៥% ពន្ធលើប្រាក់ចំណេញមានការកើនឡើងប្រមាណ ៩.៨% និងអាករលើតម្លៃបន្ថែមមានការកើនឡើងប្រមាណ ៧.៣% និងអាករពិសេស កើនឡើងប្រមាណ ១.២% ។

ការពិនិត្យតាមវិស័យឃើញថា ចំណូលក្នុងឆ្នាំ២០១៤ មានការកើនឡើងស្ទើរគ្រប់សកម្មភាពក្នុងនោះ ផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ១៩.៦% ផ្នែកស្ថាបត្យកម្មនិងសំណង់កើនឡើងប្រមាណ ៦៥.៦% ផលិតភេសជ្ជៈកើនឡើងប្រមាណ ១១.៨% ផលិតសម្លៀកបំពាក់ ៥២.៦% ផ្នែកសណ្ឋាគារនិងផ្ទះសំណាក់កើនឡើងប្រមាណ ៣៤.៥% ផលិតថ្នាំជក់កើនឡើងប្រមាណ ៣០.៧% លក់ភេសជ្ជៈកើនឡើងប្រមាណ ៤៦.៦% ផលិតម្ហូបអាហារកើនឡើងប្រមាណ ៩៥.២% លក់សម្ភារការិយាល័យកើនឡើងប្រមាណ ៤៣.៩% ដឹកជញ្ជូននិងទេសចរណ៍កើនឡើងប្រមាណ ១០.៥% អាកាសយានដ្ឋាន និងកំពង់ផែកើនឡើងប្រមាណ ២០% និងផ្នែកលក់គ្រឿងយន្ត កើនឡើងប្រមាណ ២៨.៥%។

ក្នុងការពិភាក្សាអង្គប្រជុំបានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា I-ពិភាក្សាពីការប្រមូលចំណូលពន្ធដារដែលប្រមូលដោយនាយកដ្ឋាននិងសាខាពន្ធដារខេត្ត-ខណ្ឌ ក្នុងខែមេសា ឆ្នាំ២០១៤ កន្លងមក II-ពិភាក្សាពីការបង់ពន្ធលើអចលនទ្រព្យប្រចាំឆ្នាំ២០១៤ និងពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ III-របាយការណ៍វឌ្ឍនភាពស្តីពីកិច្ចការចាត់បញ្ចូលមូលដ្ឋានអាជីវកម្មជាប់ពន្ធតាមរបបម៉ៅការទៅរបបស្វ័យប្រកាស និងទី IV-វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពដោះស្រាយបញ្ហាជាក់ស្តែងរបស់អគ្គនាយកដ្ឋានពន្ធដារ (ដោយផ្តោតជាសំខាន់លើកិច្ចការផ្តល់សេវាដល់អ្នកជាប់ពន្ធ)។

ដើម្បីប្រមូលចំណូលបានគ្រប់តាមផែនការច្បាប់សម្រាប់ឆ្នាំ២០១៤ និងបណ្តាឆ្នាំបន្តបន្ទាប់ខាងមុខ ជាពិសេស ដើម្បីធានាបាននូវភាពជឿទុកចិត្តផ្នែកថវិកាសម្រាប់បម្រើកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងជំរុញការអនុវត្តឲ្យកាន់តែជោគជ័យថែមទៀត នូវកំណែទម្រង់ស៊ីជម្រៅសំខាន់ៗរបស់រាជរដ្ឋាភិបាលនីតិកាលទីប្រាំនៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាពិសេស ការបង្កើនប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ អគ្គនាយកដ្ឋានពន្ធដារមានទិសដៅត្រូវអនុវត្តបន្តដូចខាងក្រោម÷

- បន្តជំរុញអនុវត្តនូវគោលការណ៍ និងផែនការសកម្មភាពការងាររបស់អគ្គនាយកដ្ឋានពន្ធដារ ដែលបានដាក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កន្លងមក ឲ្យបានដូចភ្លៀងរលឹម ជាពិសេសយុទ្ធនាការនៃការចាត់បញ្ចូលទៅរបបស្វ័យប្រកាសនូវអាជីវកម្មបង់ពន្ធតាមរបបម៉ៅការដែលមានផលរបរខ្ពស់ ដោយដាក់ផែនការចាត់បញ្ចូលអាជីវកម្មដ្ឋានដែលស្ថិតក្នុងរដ្ឋបាលដែនដីនៃខេត្ត-ខណ្ឌនីមួយៗ ទៅក្នុងរបបស្វ័យប្រកាសឲ្យបានត្រឹមត្រូវតាមការកំណត់កំរិតផលរបរដូចមានចែងក្នុងប្រកាសលេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ។
- បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់និងប្រកបដោយប្រសិទ្ធភាពខ្ពស់នូវសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដែលបានទទួលនូវការឯកភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** តាមរយៈលិខិតលេខ៩០០៦ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- ក្នុងខែឧសភា ឆ្នាំ២០១៤នេះ អគ្គនាយកដ្ឋានពន្ធដារ នឹងដាក់ឲ្យអនុវត្តការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ នៅតាមសាខាធនាគារ កាណាឌីយ៉ា ក.អ កម្ពុជា ឬ នៅតាមសាខាធនាគារ អេស៊ីលី ភីអិលស៊ី ហើយគ្រោងនឹងដាក់ឲ្យអនុវត្តជាបន្តបន្ទាប់នូវការបង់ពន្ធនៅតាមគ្រប់សាខារបស់ភ្នាក់ងារ Wing ទាំងអស់ ដែលការដាក់ឲ្យអនុវត្តរបៀបនេះ គឺក្នុងបំណងបង្កលក្ខណៈងាយស្រួលជូនអ្នកជាប់ពន្ធក្នុងការបង់ពន្ធ ក៏ដូចជាដើម្បីកាត់បន្ថយរាល់ចំណុចអសកម្មនានារបស់មន្ត្រីពន្ធដារ ដែលតែងតែត្រូវបានលើកឡើងនូវការមិនពេញចិត្តពីសំណាក់អ្នកជាប់ពន្ធ នាពេលកន្លងមក។
- បន្តតាមដាននិងចាត់វិធានការចុះធ្វើសវនកម្មឲ្យបានទាន់ពេលវេលាទៅលើវិស័យមួយចំនួនដែលអគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា សកម្មភាពអាជីវកម្មមានការកើនឡើងយ៉ាងគគ្រឹកគគ្រេង ប៉ុន្តែការប្រកាសបង់ពន្ធរបស់វិស័យទាំងនោះបែរជាមានការធ្លាក់ចុះ ឬប្រកាសពន្ធទាបដែលមិនអាចទទួលយកបាន។

ជាកិច្ចបញ្ចប់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលមានការកើនឡើងគួរជាទីពេញចិត្ត និងផ្តល់អនុសាសន៍ណែនាំបន្ថែមដល់អស់លោកជាប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់និងមន្ត្រីពន្ធដារទាំងអស់ឲ្យខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារ ឲ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់

ពន្ធជូនរដ្ឋ  និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធដើម្បីការប្រមូលពន្ធឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីឈានទៅសំរេចបានតាមផែនការក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។



**អគ្គនាយកដ្ឋានពន្ធដារ**